# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ ញាញ រុន

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ញាញ រុន

កៈ ចាសជាដំបូងសូមជំរាបសួរអ៊ុំ!

ខៈ ចាស!

កៈ ចាសអ៊ុំខ្ញុំធ្វើការនៅខាងគំរោងរបស់ខាងសាលា BYU នៅខាងសហរដ្ឋអាមេរិចណាស់អ៊ុំ!

ខៈ ចាស!

កៈ
ហើយគំរោងរបស់ខាងសាលាមួយនឹងគឺជួយចងក្រងនូវពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី
៣៥ឆ្នាំឡើងអំពីជីវិតបទពិសោធន៍ដែលគាត់ធ្លាប់បានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥលូវថាតើគាត់ធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ជីវិតអីគេខ្លះដើម្បីនឹងទុកអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ដែរណាស់អ៊ុំ?

ខៈ ចាស!

កៈ ចាស!
អញ្ចឹងជាដំបូងនៃការសំភាសនឹងតើអ៊ុំអនុញ្ញាតអោយខ្ញុំធ្វើការសំភាសន៍អ៊ុំដោយដាក់សំលេងរបស់អ៊ុំនៅក្នុងវេបសាយនឹងហើយនឹងអឺ...រូបថតរបស់អ៊ុំដែលខ្ញុំបានថតអ៊ុំមិញនឹងណាស់....

ខៈ ចាស!

កៈ ដាក់នៅក្នុងវេបសាយដែរឬទេអ៊ុំ?

ខៈ ចាស!

កៈ ចាសអរគុណច្រើនអ៊ុំ! អញ្ចឹងមុនដំបូងការសំភាសន៍នៅក្នុងថ្ងៃនឹងគឺជាថ្ងៃទី ២៨ ខែ៧ ឆ្នាំ ២០១៧...១៨!

ខៈ ចាស!

កៈ ចាស! ហើយការសំភាសន៍មុនដំបូងសូមសួរឈ្មោះរបស់អ៊ុំតើអ៊ុំមានឈ្មោះអីដែរ?

ខៈ ខ្ញុំឈ្មោះ ញាញ សារុន!

កៈ ចាស! ហើយ...

ខៈ ញាញ សារុន!

កៈ ចាសអ៊ុំ! ហើយឈ្មោះនឹងត្រូវនឹងនាមត្រកូលត្រូវនឹងអីទាំងអស់ក្នុងអត្តសញ្ញាណប័ណ្ណ?

ខៈ ចាស! នាមត្រកូល ញាញ ដាក់នៅនឹងអត្តសញ្ញាណប័ណ្ណនឹង!

កៈ ចាស!

ខៈ គេដាក់ ញាញ រុន
អញ្ចឹងម៉ងមិនបាច់ពិភាក្សាមិនបាច់អីទេនៅក្នុងអត្តសញ្ញាណប័ណ្ណគេដាក់ ញាញ រុន!

កៈ ចាសអ៊ុំ!

ខៈ ញាញ រុន!

កៈ ហើយអ៊ុំមានឈ្មោះក្រៅដែរឬទអ៊ុំ?

ខៈ អត់ទេ អត់មានទេមានតែឈ្មោះពិតតែមួយនឹង!

កៈ ឈ្មោះនឹងមានអត្ថន័យយ៉ាងណាដែរចំពោះអ៊ុំ?

ខៈ (សើច)
អត់ដឹងដែរពីឪពុកម្ដាយគាត់ដាក់មកមិនដឹងថាមានអត្ថន័យយ៉ាងម៉េចអត់ដឹងដែរ(សើច)!

កៈ ចាស! អ៊ុំឥលូវនឹងអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំអាយុ៧២ឆ្នាំហើយ!

កៈ ចាស! អ៊ុំកើតនៅក្នុងឆ្នាំណាដែរ?

ខៈ ឆ្នាំ១៩៤៥!

កៈ ចាស! អ៊ុំហើយទៅចាំឆ្នាំចន្ទគតិរបស់ខ្មែរយើងអ៊ុំដឹងដែរទេ?

ខៈ អត់...អត់ចាំ!

កៈ ដូចឆ្នាំ ឆ្លូវ ឆ្នាំជូត ខាល ថោះ អីនោះអ៊ុំ ឆ្នាំសត្វ...

ខៈ អូ...អ៊ុំឆ្នាំច អ័...ឆ្នាំកុរ!

កៈ អូ...ចាសអ៊ុំ! ហើយចុះថ្ងៃខែវិញអ៊ុំចាំដែរទេ?

ខៈ ថ្ងៃអឺ...ថ្ងៃពុធ ខែ...ខែមាឃធំ!

កៈ ចាសអ៊ុំ! អញ្ចឹងអឺ...ស្រុកកំណើតរបស់អ៊ុំនឹងអ៊ុំកើតនៅឯណាដែរ?

ខៈ ខ្ញុំកើតនៅនឹង ស្រុកព្រែកញ្ចៀ ខេត្តព្រៃវែង!

កៈ ចាសនៅភូមិឃុំអីគេដែរអ៊ុំ?

ខៈ អូ...ភូមិល្វា ឃុំល្វា!

កៈ ចាសអ៊ុំ!

ខៈ នៅជាប់ថ្នល់ជាតិផ្លូវ អឺ...ផ្លូវជាតិតលេខមួយនឹង!

កៈ ចាសអ៊ុំ! ហើយអ៊ុំមានបងប្អូនប៉ុន្មាននាក់?

ខៈ អូ...មានបងប្អូនតែបួននាក់!

កៈ ចាស! ស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ៊ុំ?

ខៈ ស្រីបីប្រុសមួយ!

កៈ ចាស! ហើយអ៊ុំជាកូនទីប៉ុន្មាននៃគ្រួសារ?

ខៈ អ៊ុំជាកូនទីមួយ!

កៈ អូ...អញ្ចឹងអ៊ុំជាបងគេន៍អ៊ុំ?

ខៈ បងគេបង្អស់!

កៈ ចាស! ហើយទៅគាត់មានឈ្មោះអីគេខ្លះទៅបងប្អូនរបស់អ៊ុំ?

ខៈ មួយឈ្មោះ ញាញ សារិន មួយទផតឈ្មោះ ញាញ ជា មួយទៀតនឹងឈ្មោះ ញាញ គង់!

កៈ ចាសអ៊ុំ! អ៊ុំចងចាំនឹងរឿងអីគេខ្លះជាមួយនឹងបងប្អូនរបស់អ៊ុំ?

ខ៖ អឺម! បងប្អូនរបស់អញ្ចេកតាំងពីកើតមកក្នុងប្រវត្តិរបស់អ៊ុំគឺមិនមានពិបាកអីទេពីសង្គមចាស់ណាស់! នៃ...អត់មានសោមន្ស្សអីជាមួយគ្នាមានតែការរស់នៅជាមួយនឹងឪពុកម្ដាយសុខសប្បាយរហូតទាល់តែមានក្រុមគ្រួសាររៀងៗខ្លួន!

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងអ៊ុំកាលពីអ៊ុំនៅក្មេងៗអ៊ុំចូលចិត្តអីគេខ្លះជាមួយនឹងពួកគាត់ដែរអ៊ុំ?

ខ៖ លេង...លេងពីដើមមានតែលេងបិទពួន លេងលាក់កន្សែង លេងលាក់កូនមាន់អីនឹងពីសង្គមណាស់!

ក៖ អូ...ចាស!

ខ៖ គ្មានចេះលេងអីទេ គ្មានចេះលេងរបាំប្រជាប្រិយអីអត់មានទេ!

ក៖ ចាស!

ខ៖ អឺម!

ក៖ ចាសអ៊ុំ! អញ្ចឹងឥលូវពួកគាត់នៅឯណាហើយពួកគាត់ធ្វើអីខ្លះទៅបងប្អូនរបស់អ៊ុំ?

ខ៖ អឺម...បងប្អូនរបស់ខ្ញុំឥលូវសព្វថ្ងៃនៅឯស្រុកឯណោះ នៅឯស្រុកនឹងគ្នាធ្វើមុខរបររកស៊ីធ្វើស្រែនឹង គ្មានធ្វើអីទេនៅប៉ុណ្ណឹងមកដល់កូនៗទៅបានមានទិន្នាការខ្លះធ្វើប៉ូលីសខ្លះធ្វើប៉េអឹម អីអញ្ចឹងទៅ!

ក៖ អូ..ចាសអ៊ុំ! អញ្ចឹងឪពុកម្ដាយរបស់អ៊ុំវិញគាត់មានឈ្មោះអីដែរ?

ខ៖ ឪពុកម្ដាយ ឪពុករបស់ខ្ញុំឈ្មោះ ញាញ វ៉ន ម្ដាយរបស់ខ្ញុំឈ្មោះ ពូរ រុំ!

ក៖ ចាសអ៊ុំ! ហើយគាត់អាយុប៉ុន្មានហើយអ៊ុំ?

ខ៖ គាត់ស្លាប់អស់ហើយ...

ក៖ គាត់ស្លាប់នៅក្នុងអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ គាត់ស្លាប់អាយុ៨០ចូល៩០ហើយម្ដាយខ្ញុំនឹងស្លាប់អស់ហើយ!

ក៖ អូ...

ខ៖ ម្ដាយស្លាប់បានប្រាំខែបែក...បែកប៉ុលពត!

ក៖ ចាស!

ខ៖ ឪពុកទើបតែស្លាប់ដែរ!

ក៖ អូ...ស្លាប់ដោយសារជំងឺអី...ជរា...

ខ៖ គាត់ជរាឡើងឈាម!

ក៖ ចាស!

ខ៖ ហើយម្ដាយរោគបេះដូង សំរាន្តទៅគាំងស្លាប់ម៉ង!

ក៖ អឹម...ចាស!
ចាសអ៊ុំទាក់ទងជាមួយនឹងអឺ...អ៊ុំដឹងអីគេខ្លះពីពួកគាត់ណាស់ដូចជាគាត់កើតនៅក្នុងឆ្នាំណា នៅកន្លែងណា?

ខ៖ គាត់កើតបើគាត់ខ្ញុំដឹងតែឆ្នាំកើតឪពុករបស់ខ្ញុំឆ្នាំ ឆ្លូវ ហើយម្ដាយខ្ញុំឆ្នាំ ខាល កំណើតកើតជារបស់គាត់នៅនឹងព្រៃវែងទាំងអស់!

ក៖ ចាស!
អ៊ុំហើយអញ្ចឹងដូចជាឪពុកម្ដាយរបស់អ៊ុំគាត់ប្រកបមុខរបរអីគេដែរដើម្បីចិញ្ចឹមជីវិតដែរ?

ខ៖ គាត់មុខប្រកបមុខរបរធ្វើស្រែនឹង!

ក៖ ទាំងពីរនាក់នឹងតែម្ដងហ៎លោកយាយ?

ខ៖ ចាស!

ក៖ ចាសហើយអញ្ចឹងគាត់ជាមនុស្សប្រភេទណាដែរលោកយាយ?

ខ៖ មនុស្សគាត់នឹងមនុស្សប្រភេទអាចារ្យបួស
បួសហើយក្រោយមកពីសឹងមកគាត់ធ្វើអាចារ្យវត្ត!

ក៖ ចាស!

ខ៖ ឪពុកខ្ញុំ!

ក៖ អញ្ចឹងអ៊ុំចងចាំរឿងអីគេខ្លះជាមួយនឹងឪពុកម្ដាយរបស់អ៊ុំ?

ខ៖
ចងចាំរឿងរបស់ឪពុកនឹងឪពុករបស់ខ្ញុំការចិញ្ចឹមកូនឬក៏គាត់ខំប្រឹងប្រែងខិតខំរកស៊ីចិញ្ចឹមកូន ហើយគាត់ក៏ជាមនុស្សគេគោរពរាប់អានគេស្រលាញ់ព្រោះអីគាត់ជាអាចារ្យគាត់មានសីលមានធម៌អាត្រឹមត្រូវណាស់ឪពុកខ្ញុំនឹង!

ក៖ អឺម!

ខ៖ ស្លាប់ក៏មិនពិបាកដែរអាយុ ៨០ឆ្នាំនឹងគាត់ស្លាប់ អាយុប៉ុណ្ណឹងព្រះដែរបានគាត់ស្លាប់!

ក៖ ចាស!

ខ៖ ស្លាប់ទៅឡើងស្រួលអត់មានពិបាកទេ!

ក៖ ចាស!
អញ្ចឹងអ៊ុំដូចជាជីវិតរបស់គាត់តាំងតែពីគាត់នៅពីក្មេងមកគាត់មានដែលប្រាប់អ៊ុំដែរឬទេ?

ខ៖ អឺម! គាត់...គាត់ថីម៉េចក៏មិនប្រាប់គាត់ប្រាប់ថាជីវិតរបស់គាត់
កើតតាំងតែពីគាត់កើតមកនៅជាមួយនឹងម្ដាយឪពុករបស់គាត់
អើ...កាលពីដើមវាខ្វះខាតក្រលំបាកដែរណាស់អឹម...ពីដើមណាស់បើនិយាយរឿងដែលពិបាកវេទនាពីដើមម្ដាយរបស់ខ្ញុំគាត់និយាយថា
ចង់ស្លៀកកាបាស់លោកតាខ្ញុំរវៃកបាស់ធ្វើជាខោអាវស្លៀកណាស់
ស្លៀកពាក់ដែលគ្មានសំលៀកបំពាកវាក្រហើយកូនក៏វាច្រើនអញ្ចឹងឯងទៅ
គាត់ដាំកបាស់រវៃកបាសនឹងរវៃកបាសនឹងធ្វើជាភួយជាអីនឹងអោយកូនដណ្ដប់!

ក៖ អូ...

ខ៖ អានឹងគាត់និយាយប្រវត្តិរបស់គាត់ ប្រាប់ខ្ញុំ!

ក៖ អូ...

ខ៖ ហើយនៅកាលនោះក្រណាស់ កាលជំនាន់នឹងពីសង្គមចាស់ពីដើមនឹង!

ក៖ ចាស!

ខ៖ ស្លៀកកបាសស្លៀកខ្លះគេស្លៀកគរស្លៀកកបាស កើតចែ!

ក៖ អូ...

ខ៖ អូ...ហើយខ្លះដូចថាគ្នាក្រពេកទៅនឹងមានតែមួយចង្កេះឆ្អេះនឹងខ្លួន
ដល់ពេលថ្ងៃនឹងទៅ...ទៅក្នុងព្រៃស្វាត់អញ្ចឹងឯងទៅលបស្រោតហាលអោយចែវាវាចេញណា
ស់ នឹងគេទេបើឪពុកម្ដាយរបស់ខ្ញុំគាត់អត់ទេ
គាត់មិនបានទេគាត់ស្លៀកតែខោអាវសហើយទៅគាត់ត្បាញសំឡីនឹងគាត់អឺ...ធ្វើនៃ...

ក៖ ចាស!

ខ៖ ធ្វើជាភួយជាអីចែកកូនដណ្ដប់ព្រោះតាខ្ញុំកូនរបស់គាត់១២នាក់!

ក៖ ចាសអ៊ុំ!

ខ៖ ចិញ្ចឹមកូនរបស់គាត់ដល់ធំរស់
ដល់មកទទួលសម័យគេដៃរវាសម្បូរសប្បាយនឹងគាត់ក៏លែងពិបាក!

ក៖ ចាស!
ចាសអ៊ុំអឺ...ទាកទងជាមួយនឹងជីដូនជីតារបស់អ៊ុំវិញតើអ៊ុំមានចាំឈ្មោះរបស់ពួកគាត់ដែរឬទេ
ទាំងខាងឪពុកនឹងខាងម្ដាយរបស់អ៊ុំណាស់?

ខ៖ ចាំតារបស់ខ្ញុំឈ្មោះ តាញាញ ដែលត្រកូលខាងឪពុកណាស់
អឺម...ដល់ប្អូនខាងម្ដាយយាយ...យាយខ្ញុំឈ្មោះយាយ ហេង
អឺម...ដល់ម្ដាយឪពុកខាងម្ដាយឈ្មោះ តាគោ គាត់អារើសណាស់គេដាក់ឈ្មោះតាគោណាស់!

ក៖ ចាស!

ខ៖ អឺម! ដល់ពេលម្ដាយយាយខ្ញុំនឹងគាត់ឈ្មោះយាយ ហេងអ៎...យាយៗហ៊ឹម
តាគោយាយហ៊ឹម អឺម!

ក៖ (សើច) ចាសៗអ៊ុំ! ហើយទាកទងជាមួយនឹងកើតនៅឯណាហើយឆ្នាំណាអ៊ុំដឹងដែរឬទេ?

ខ៖ អត់ដឹងទេមិនបានចាំទេវាវែងឆ្ងាយណាស់!

ក៖ ចាស! ចុះអ៊ុំមានធ្លាប់ដឹងអំពីរឿងរបស់ពួកគាត់ដែរឬទេ?

ខ៖ ពួកបើពួកគាត់គឺកំសត់វេទនាស្លៀកគរ ស្លៀកបាសតាំងពីជំនាន់នឹងន៏!

កៈ អូ...

ខៈ វេទនាណាស់!

កៈ អ៊ឹម...ចាសអ៊ុំ!
ហើយទាកទងជាមួយនឹងក្រុមគ្រួសារវិញអ៊ុំដូចជាអ៊ុំនៅខាងខេត្តណាស់នៅស្រុកកំណើតអស់រយៈពេលយូរប៉ុន្មានដែរ?

ខៈ ខ្ញុំទើបតែមកនៅនឹងភ្នំពេញឆ្នាំ២០០៦នឹងតើ!

កៈ អ៊ឹម!

ខៈ
ខ្ញុំនៅ...ខ្ញុំនៅឯស្រុកនឹងបានយូរណាស់ទើបតែដូរមកនៅនឹងភ្នំពេញនឹងឆ្នាំ២០០៦នឹងបានមកនៅជាប់ភ្នំពេញនឹង!

កៈ ចាស!

ខៈ មានផ្ទះមានអីមានកូនមានអីមានប្រពន្ធមានអីមកនៅនឹងៗហើយខ្ញុំក៏មកនៅតាមកូន កូនខ្ញុំចាសមានតែកូនមួយវាស្លាប់ចោលខ្ញុំទៅសល់ចៅបួននាក់ដែលខ្ញុំចិញ្ចឹមវារហូតដល់ធំក្រមុំកំលោះអស់ខ្លះមានប្តីមានអីនឹងដោយសារខ្ញុំមកនៅនឹងភ្នំពេញនឹងដោយសារកូនវាស្លាប់ទៅចោលចៅកំព្រើកំព្រាទៅបានខ្ញុំចូលខ្លួនមកចិញ្ចឹមចៅ!

កៈ ចាសអ៊ុំ! អញ្ចឹងអ៊ុំមានបងប្អូនសាច់ញាតិនៅនឹងប្រទេសក្រៅដែរឬទេអ៊ុំ?

ខៈ អត់ទេ ខ្ញុំអត់មានផង!

កៈ អ៊ឹម!
ចុះទាកទងជាមួយនឹងអាពាហ៍ពិពាហ៍វិញអ៊ុំ...អ៊ុំប្រុសត្រូវជាប្តីរបស់អ៊ុំគាត់ឈ្មោះអីដែរ?

ខៈ គាត់ឈ្មោះ ប្រាក់ សៀន!

កៈ កាលនឹងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរអ៊ុំ?

ខៈ រៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ...ឆ្នាំអីអញ្ចេះវ៉ីភ្លេចបាត់ហើយ!

កៈ ចាសអ៊ុំ!

ខ៖ ឆ្នាំរោងការនៅក្នុងឆ្នាំរោង!

ក៖ ឆ្នាំមួយពាន់...

ខ៖ ហើយឆ្នាំម្សាញ់កើត...ឆ្នាំម្សាញ់មានកូន ការដឹងតែថាឆ្នាំរោងប៉ុន្តែមិនដឹងថាមួយពាន់ប៉ុន្មានអីប៉ុន្មានទេ?

ក៖ កាលនឹងនៅជំនាន់សង្គមរាស្ត្រនិយមហ៎?

ខ៖ ចាស១! នៅក្នុងសង្គមរាស្ត្រនិយមនៅឡើយទេ!

ក៖ ចាស! ហើយចុះអាពាហ៍ពិពាហ៍កាលនឹងឪពុកម្តាយគាត់ជាអ្នករៀបចំទុកដាក់អោយឬក៏អ៊ុំស្រលាញ់គ្នា?

ខ៖ អត់ទេ ម៉ែ...ម៉ែឪទុកដាក់ គាត់ផ្ទុកផ្តើមរៀបចំខ្ញុំអត់ទៅមានស្រលាញ់អីដោយខ្លួនឯងទេ!

ក៖ ចាស! មានជំនូនដែរឬអត់អ៊ុំកាលនឹង?

ខ៖ ហ្អាស់? មាន...មានហើយនៅកាលនោះគេការអីបានត្រឹមត្រូវមានជំនូនអីត្រឹមត្រូវ!

ក៖ អូ...ចាស! (និយាយរឿងផ្សេង)! ហើយអឺ...អ៊ុំនិយាយថាអ៊ុំអាចប្រាប់ខ្ញុំបានទេថាពីកាលមុនដំបូលដែលអ៊ុំបានជួបនឹងលោកតាដែលត្រូវជាស្វាមីរបស់អ៊ុំដំបូងនឹងនៅពេលណាដែរ?

ខ៖ នៅកាលនឹងខ្ញុំអាយុ១៧ឆ្នាំ ខ្ញុំឈប់រៀនបានមួយឆ្នាំគេមកដណ្តឹងរៀបការ!

ក៖ អឺម! ចាសអ៊ុំ! អញ្ចឹងនៅពេលនឹងទាល់តែរៀបការហើយបានស្គាល់គ្នា(សើច)?

ខ៖ ចាសរៀបការហើយបានស្គាល់គ្នាខ្ញុំអត់មាន(សើច) ដូចគេឥលូវនឹងគេស្គាល់គ្នាហើយបានការនឹងខ្ញុំមិនដែលបានស្គាល់ផងរហូតមកដល់ថ្ងៃការម៉ង!

ក៖ (សើច)!

ខ៖ បើយើងនៅឆ្ងាយពីគ្នា៤០គីឡូកាលនឹងមានស្អីមានតែកង់មានតែស្អីទៅមានឡានមានម៉ូតូឯណាគាត់នៅនឹងស្រុកក្បែរព្រំដែនវៀតណាមឯណោះ ខ្ញុំនៅផ្ទល់ជាតិលេខមួយនេះ!

កៈ ចាសអ៊ុំ! អ៊ុំហើយអ៊ុំអាចចេះភាសាខ្មែរយើងអាចអានបានហើយនឹងសរសេរបានល្អដែរទេអ៊ុំ?

ខៈ ខ្ញុំសរសេរបាន!

កៈ អូ...តែបើភាសាផ្សេងពីនឹងវិញអ៊ុំ?

ខៈ អត់ចេះទេ!

កៈ កាលនឹងអ៊ុំបានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទីប្រាំបីពីសង្គមនឹងរៀនបានត្រឹមថ្នាក់ទីប្រាំបី!

កៈ ចាស! រៀននៅសាលាណាដែរអ៊ុំ?

ខៈ សាលាល្វានឹង!

កៈ នៅខាង...

ខៈ ស្រុកភូមិល្វានឹង ភូមិខ្ញុំនឹង!

កៈ ចាស! កាលនឹងអ៊ុំមានមិត្តភក្តិស្និទ្ធស្នាលដែរឬទេ?

ខៈ ខ្ញុំមិនសូវជាមានមិត្តភក្តិអីច្រើននឹងគេទេ បើចេញតែពីរៀនមកផ្ទះហើយខ្ញុំពីដើមដូចជាគ្មានមិត្តភក្តិដូចឥលូវនឹងទេ!

កៈ អឺម...ចាស! អ៊ុំធ្លាប់ធ្វើស្រែចំការដែរឬទេអ៊ុំ?

ខៈ ធ្លាប់!

កៈ អញ្ចឹងមានន័យថាឪពុកម្តាយរបស់អ៊ុំជាកសិករហ៎អ៊ុំ?

ខៈ នឹងហើយជាកសិករ!

កៈ ការងារដែលអ៊ុំធ្លាប់ធ្វើពីមុនឡើយនឹងមានអីគេខ្លះដែរដើម្បីនឹងចិញ្ចឹមជីវិតតាំងតែពីមុនរហូតមកដល់ឥលូវនឹងអ៊ុំមានការងារអីខ្លះទៅ?

ខៈ ការងារអីទេ មានតែការងារធ្វើស្រែនឹងធ្វើស្រែចិញ្ចឹមជីវិតទៅ!

កៈ ចាស!

ខៈ ព្រោះអីយើងអត់មានលទ្ធិភាពអីឯណាដាក់ទៅធ្វើអីៗឯណាមានតែធ្វើស្រែចំការនឹង អ្នកស្រុកខ្ញុំមិនសូវមានចំការទេមានតែស្រែ!

កៈ អឹម!

ខៈ ធ្វើស្រែមុខរបររកស៊ីធ្វើស្រែ!

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំកើតជាតិនឹងខ្ញុំកំសត់លំបាកវេទនា ហើយពេលខ្ញុំមកមានគ្រួសារមកមានតែកូនមួយកូនវាស្លាប់ចោលខ្ញុំតាំងពី២០០២ ស្លាប់ចោលទុកចៅអោយខ្ញុំចិញ្ចឹម!

កៈ អឹម! អ៊ុំមានកូនប៉ុន្មាននាក់?

ខៈ កូនខ្ញុំមានតែមួយទេ មានតែកូនប្រុសមួយមកដណ្ដឹងប្រពន្ធការនៅស្រុកនឹងណាស់នៅភ្នំពេញនឹងណាស់!

កៈ ចាស! ហើយកូននឹងគាត់មានឈ្មោះអីដែរអ៊ុំ?

ខៈ កូន ឥន្ទ សុគន់!

កៈ ចាស! ហើយគាត់ស្លាប់ទៅនឹងអាយុប៉ុន្មាន?

ខៈ អាយុ ៣៨ឆ្នាំ!

កៈ អូ... សោកស្ដាយមែនទែននៅសល់ចៅអោយអ៊ុំមើល!

ខៈ ចៅបួសទើបតែនឹងសឹកបានមួយខែ បួសប្រាំប្រាំមួយឆ្នាំទើបតែសឹងនឹង!

កៈ អឹម!

ខៈ គាត់...

កៈ គាត់បួសនៅវត្តនឹងហ៎អ៊ុំ?

ខ៖ បួសនៅវត្តនឹងសឹកនឹងរៀនវិស្វករ
រៀនឆ្នាំទីបីហើយឥលូវនឹងកំពុងរៀនមិនទាន់ចប់ផងចៅពៅគេហើយនឹងណាស់
កាលពីឪពុកស្លាប់អាយុបួនឆ្នាំ!

ក៖ ចាស!
អូ...ហើយអ៊ុំអញ្ចឹងជីវិតរបស់អ៊ុំដូចជាមានកូនតែមួយហើយស្វាមីរបស់អ៊ុំលោកតាគាត់នៅមានព្រះជន្មរស់តើហី?

ខ៖ នៅមានព្រះជន្មរស់សព្វថ្ងៃនឹងពិបាកដើរអត់រួចទេ
រោគទឹកនោមផ្អែមកំពុងតែឈឺចាប់ជើងស្រែកអោយរាល់តែថ្ងៃរកលុយទៅពេទ្យមិនបានទេកូនអើយ!

ក៖ អ៊ឹម! អញ្ចឹងអ៊ុំធ្វើម៉េចទៅដើម្បីនឹងចិញ្ចឹមគ្រួសារនឹងមានលុយសំរាប់ផ្គត់ផ្គង់គ្រួសារ?

ខ៖ ខ្ញុំរាល់ថ្ងៃនឹងបានអឺ...តាគាត់មាននៅប្រាក់បៀវត្តន៍របស់គាត់ធ្វើគ្រូ!

ក៖ ចាស!

ខ៖
មានប្រាក់ឧបត្ថមប្រាក់អាត្រែតគាត់បន្តិចបន្តួចនឹងគាត់អាត្រែតយូរហើយបានលីខ្ញុំខ្លះហើយលុយដែលបានមកពីការជួលស្រែជួលដីអោយគេទៅនៅឯស្រុកនឹងណាស់បានខ្លះៗចេះតែប្រឹងប្រែងតស៊ូទៅតែឥលូវធ្លាក់ខ្លួនហើយ
ដល់តែគ្រួសារឈឺទៅរកលុយរកកាក់យកទៅពេទ្យណាក៏មិនបានដែរនៅស្រែក
ពេលណាឈឺចាប់នៅស្រែកយប់មិញនឹងឈឺមួយយប់ហើយ!

ក៖ អ៊ឹម! តែទាល់ពេលអ៊ុំអត់អីទេហ៎សុខភាពអី?

ខ៖ ខ្ញុំអត់អីទេ! (និយាយគ្នារឿងផ្សេង)!

ក៖ ចាស!

ខ៖ គិតអញ្ចឹង!

ក៖
អញ្ចឹងអ៊ុំជីវិតរបស់អ៊ុំតាំងពីមុនរហូតមកដល់ឥលូវនឹងអ៊ុំឆ្លងកាត់ជាមួយនឹងបទពិសោធន៍ច្រើនអញ្ចឹងហើយ!

ខ៖ ច្រើនណាស់!

ក៖ ហើយអឺ...វាមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំតាំងពីអ៊ុំនៅក្មេងរហូតមកដល់ឥលូវនឹង?

ខ៖
ពីក្មេងរហូតមកទល់ឥលូវនឹងផ្លាស់ប្តូរមកដល់សម័យគេនេះនោះសម័យគេឥលូវនេះនឹងវាដូច
ថាវាមិនពិបាកដូចសង្គមគេពីដើមការហាត់នឿយធ្វើស្រែធ្វើចំការអីណាស់!

ក៖ ចាស!

ខ៖ មកនៅនឹងវត្តនឹងអញ្ចឹងទៅគ្រាន់បានកំរៃគេមកអញ្ចឹងគេជូនទៅ
ខ្លះបើមានសព្វមានសព្វមានអីគេមកគេហៅទៅសូត្រធម៌សូត្រអីអោយគេទៅ!

ក៖ ចាស!

ខ៖ គេជូនលុយជូនកាក់អីទៅចេះតែចិញ្ចឹមជីវិតទៅរាល់ថ្ងៃនឹងណាស់!

ក៖ ចាសៗអ៊ុំ!

ខ៖ ជូនណាគេអ្នកមានទៅគេជូនបួន ប្រាំម៉ឺនទៅមួយយប់ជូនកាលពីរម៉ឺន បីម៉ឺន
មួយម៉ឺនអីអញ្ចឹងទៅដែលមកនៅបំរើលោកនឹងណាស់!

ក៖ ចាស!

ខ៖ សព្វថ្ងៃនឹងណាស់!

ក៖ ចាសនឹងហើយអ៊ុំ!
ហើយទាកទងជាមួយនឹងអ៊ុំរាល់ថ្ងៃនឹងចូលចិត្តពិសារមុខម្ហូបអីគេខ្លះដែរតាំងពីតូចមកដល់ឥ
លូវនឹងណាស់អ៊ុំ?

ខ៖ អឹម...រឿងមុខម្ហូបតាំងពីក្មេងមកស្អីក៏ហូបបានដែរដល់ឥលូវនឹងហូបអត់បាន
បានតែត្រីងៀតបានតែស្អី!

ក៖ ចាស!

ខ៖ ផ្អេសផ្អាសនឹង!

ក៖ ហើយល្បែងកាលពីនៅក្មេងៗនឹងអ៊ុំចូលចិត្តលេងដែរឬទេ?

ខ៖ អឹម...ខ្ញុំមិនសូវចូលចិត្តល្បែងអីទេលេងធម្មតា!

ក៖ អឹម...អ៊ុំកាលពីតូចនឹងធ្លាប់មានក្តីស្រម៉ៃថាធំឡើងចង់ធ្វើអីអត់អ៊ុំ?

ខ៖ អឹម! ក្តីស្រម៉ៃរបស់ខ្ញុំតែការរៀនសូត្រនឹងក្តីស្រម៉ៃប្រាថ្នាចង់ធ្វើគ្រូធ្វើអីនឹតែវាអត់បានធ្វើរហូតដល់បែកអូ...ដល់តែឈប់រៀនហើយក៏ខ្ញុំ...ខ្ញុំគេអោយខ្ញុំទៅរៀនពេទ្យឆ្មបនៅខាងខេត្តព្រៃវែង ដល់អញ្ចឹងខ្ញុំអត់អោយទៅព្រោះគាត់យល់ថាអឹម...កូនស្រីអត់អោយដើរឆ្ងាញទេអញ្ចឹងខ្ញុំក៏អញ្ចឹងទៅ!

ក៖ អឹម...ចាសអ៊ុំ!
ហើយអឺ...ដល់ពេលអញ្ចឹងអ៊ុំកាលពីនៅពីតូចនឹងអ៊ុំដូចជារៀនបានត្រឹមថ្នាក់ទីប្រាំបីហេតុអីបានជាអ៊ុំរៀនបានត្រឹមថ្នាក់ទីប៉ុណ្ណឹង?

ខ៖ ខ្ញុំពិបាកពេកម្តាយរបស់ខ្ញុំឈឺ គាត់ឆ្លងទន្លេកូនភ្លោះអត់មានអ្នកនៅជំនួសដៃជើងទៅនាំដឹងនាំគេច្រូតស្រូវច្រូតអី ជួលគេច្រូតណាស់!

ក៖ ចាស!

ខ៖
ដល់ឪពុកអ៎...ម្តាយរបស់ខ្ញុំកើតកូនភ្លោះពីរនឹងទៅគាត់ឈឺផងអីផងខ្ញុំក៏ឈប់ទៅរៀនទៅលែងទៅរៀនទៅ!

ក៖
អឹម...ចាសអ៊ុំហើយទាក់ទងអ៊ុំជីវិតបញ្ហារបស់អ៊ុំដែលអ៊ុំធ្លាប់បានជួបប្រទះតាំងពីមុនរហូតមកដល់ឥលូវនឹងអ៊ុំមានបញ្ហាអីខ្លះដែរអ៊ុំ?

ខ៖ អឹម!
មានគ្រួសារយើងមានគ្រួសារពេលណាគឺអត់ដែលបានសុខគាត់ឈឺតែរហូតឈឺៗពិបាកណាស់មើលលក់អស់ទ្រព្យសម្បត្តិអីអស់ហើយនៅតែ...ក្រោយមកបានធូរជាអញ្ចឹងឯងទៅដល់ឥលូវនឹងមកទឹកនោមផ្អែមជាប់មួយម្ភៃឆ្នាំហើយ!

ក៖ អឹម!

ខ៖ អស់លុយអស់កាក់រលីងពីខ្លួនហើយឥលូវចាប់ផ្តើមឈឺកាន់តែខ្លាំងហើយ!

ក៖ ចាស!

ខ៖ វេទនាណាស់រកតែឯង!

ក៖ ចាសអ៊ុំ!

ខ៖ រាល់ថ្ងៃខ្ញុំរស់នៅដោយពិបាកចិត្ត!

ក៖ អញ្ចឹងនៅពេលដែលអ៊ុំចាប់ដៃគ្នាមុនដំបូងណាស់អ៊ី...ចូលជំនាន់អាពតហើយត្រូវហែសអ៊ុំ?

ខ៖ អាពតនឹងតាំងពីសង្គមចាស់ម្លេះ!

ក៖ សង្គមចាស់ ដល់ពេលអ៊ុំបានកូននៅក្នុងជំនាន់អាពត?

ខ៖ បានកូននៅពេលដែលខ្ញុំបានកូន ខ្ញុំកូនរបស់ខ្ញុំអាយុ១៣ឆ្នាំកាលពីបែកប៉ុលពតណាស់!

ក៖ ចាសអ៊ុំ!

ខ៖ កូនបានអាយុ១៣ឆ្នាំហើយ!

ក៖ ចាសអ៊ុំ! អញ្ចឹងកាលពីជំនាន់នឹងគេជំលៀសអ៊ុំទៅណាដែរ?

ខ៖ គេអត់បានជំលៀសទេ
ខ្ញុំនៅនឹងស្រុកទេនៅនឹងភូមិទេអត់បានជំលៀសទៅនៅនឹងខេត្តក្រៅអូ...នែទៅខេត្តណាៗនឹង
អត់បានទៅទេបើក្រៅតែពីនឹងគេពោធិសាត់ពោធិស្អីឯណា (អ៊ុំនិយាយខាងក្រៅសាច់រឿង)!

ក៖ អញ្ចឹងកាលនឹងគេប្រើអោយលោកយាយធ្វើអីខ្លះដែរ?

ខ៖ កាលពីប៉ុលពតនឹងហ៎?

ក៖ ចាសលោកយាយ!

ខ៖ ខ្ញុំកាលពីជំនាន់ប៉ុលពតគេប្រើយាយអោយដក អោយស្ទូងអោយធ្វើការ
បើមិនអញ្ចឹងគេបញ្ចូលយាយទៅខាងរោងបាយអាបាយរួមនោះគេ
បញ្ជាអោយប្រជាជនទាំងអស់អត់អោយមានចានឆ្នាំងដាំនៅឯផ្ទះទេដកហូតអស់ដូច្នេះគេមាន
រោងបាយរួម
រួមគ្នាហូបមួយអញ្ចឹងឯងទៅមានរោងបាយមួយអញ្ចឹងឯងទៅនៅពេលហូបគេវៃអាគាំងដូចស្អី
អញ្ចឹង!

ក៖ អឺម!

ខ៖ នឹងគេ…គេបញ្ចូល (អ៊ុំនិយាយក្រៅសាច់រឿង)!

ក៖ នឹងហើយ! ហើយអញ្ចឹងលោកយាយកាលនឹងគេធ្លាប់ធ្វើ…(អ៊ុំនិយាយក្រៅសាច់រឿង) គេធ្លាប់ធ្វើបាបលោកយាយដែរឬទេកាលនឹង?

ខ៖
អត់ទេយាយដូចថាមិនបាន…គេមិនបានធ្វើបាបទេដូចថាមានបុណ្យម៉េចនៅរស់ទាល់តែឥលូវនឹងប៉ុន្តែគេធ្វើបាបត្រង់អញ្ចេកត្រង់ថាគេពេលដេញអត់អស់យ៉ាងណាស់គេអោយហូបបបរមួយកូនចានចាក់យើងប៉ុន្នឹងនេះ
ហើយកាលដែលគេចែករបបអោយដាំបាយតាមផ្ទះគេអោយម្នាក់តែកន្លះកំប៉ុងទេ
ហើយយាយហូបមិនឆ្អែតយាយលាយត្រកួន លាយផ្លែចេក លាយដំលូង
អាដំលូងដាំហើយនឹងលួចគាស់យកមកស៊ីទៀតគេអត់អោយគាស់ទៀត
ហើយវេទនាណាស់កាលពីអាពតប៉ុន្តែវាអត់ងាប់ ហូបមិនឆ្អែតទោះតែឃ្លា
នយ៉ាងណាក៏មិនដឹងទៅរកឯណាទេ!

ក៖ អឹម…ចាសលោកយាយ!
ហើយអឺ…កាលនឹងលោកយាយដែលឃើញអាពតយកមនុស្សទៅសម្លាប់ចោលដែរឬទេលោកយាយ?

ខ៖ ម៉េចក៏មិនឃើញ គេអូសយកទៅពីផ្ទះទៅសម្លាប់បាត់ៗៗទៅពិសេសពួកឆ្នាំ ៧៥(ឆ្នាំ ១៩៧៥) ដែលជំលៀសចេញពីភ្នំពេញទៅ
ទៅថាហ៎…អោយទៅធ្វើការនៅការដ្ឋាននេះនៅការដ្ឋាននោះប៉ុន្តែបាត់ខ្លួនទាំងអស់
អត់មាន…អត់មាន….អត់មាននៅទេអតមានវិលមកវិញទេ!

ក៖ ចាស!

ខ៖ ងាប់អស់រលីងពួកជំលៀសចេញពីភ្នំពេញទៅឆ្នាំ៧៥ (ឆ្នាំ១៩៧៥)
ជាពិសេសអ្នកដែលមានប្រពន្ធយូនមានប្តីយួនគឺអោយតែយូនគឺគេយកទៅសម្លាប់បាត់អស់រលីង!

ក៖ អឹម!

ខ៖ សម្លាប់គ្មានសល់ទេ!

កៈ ចាស!
អញ្ជឹងដូចជាជំនាន់នឹងដូចជាលោកយាយធ្លាប់កើតទាន់អីអញ្ជឹងលោកយាយគេធ្វើបាបផងអីផងអញ្ជឹងលោកយាយធ្លាប់ឈឺអត់?

ខៈ ឈឺឆ្នាំ៧៥ (ឆ្នាំ១៩៧៥) យាយគ្រុនមួយខែកន្លះ
គ្រុននោះគ្រុនអស់ដៃអស់ជើងកាន់ឈើច្រត់!

កៈ អូ...យាយអញ្ជឹងកាលនឹងលោកយាយឈឺអញ្ជឹងគេអោយថ្នាំយាយលេបដែរឬទេ?

ខៈ ថ្នាំបុរាណរបស់ប៉ុលពត!

កៈ អូ...ចាស!

ខៈ ថ្នាំគេនឹងមិនដឹងគេធ្វើពីស្អីៗមកយកមក
យាយគ្រុនមួយខែកន្លះយាយគ្រុនពីរដឹងវាក្តៅពេក!

កៈ អូ...អញ្ជឹងយាយកាលនឹងយាយចាំទិដ្ឋភាពអីគេខ្លះដែរជំនាន់ប៉ុលពតណាស់?

ខៈ ទិដ្ឋភាពនឹងគឺវាស្គាល់អស់ហើយទុក្ខលំបាវេទនាម៉េច
ហើយទៅនៅខាងស្រុកប្តីអី...ពួកអាខាងភាគីវៀតណាមនឹងវាផ្លោងកាត់ភូមិយាយអាទារីរាប់សិបគ្រាប់សុទ្ធតែរណ្តៅគ្រាប់!

កៈ អីគេយាយទារី?

ខៈ គ្រាប់អាទារីអាធំៗដែលគេផ្លោងមកនោះ គ្រាប់ផ្លោងនោះ!

កៈ អូ...ចាស!

ខៈ ដាក់ផុងមក
ផុងឆេះផ្ទះឆេះគោងាប់អីបានយាយរត់ៗរត់មកនៅស្រុករបស់ខ្ញុំវិញមកនៅឯជិតថ្នល់ជាតិឯណោះដល់ពេលគេរំដោះបែកនឹងខ្ញុំរត់មកចូលភ្នំពេញនឹងលន់នល...លន់នល
ខ្ញុំមកនៅនឹងភ្នំពេញនឹងតើជំនាន់លន់នលនឹង!

កៈ អឺម! ចាសយាយ
ហើយដល់ពេលរត់មកនៅពេលដែលជំនាន់ប៉ុលពតនឹងដាច់នឹងលោកយាយប្រកបមុខរបរធ្វើអីដែរធ្វើស្រែចំការ?

ខ៖ ខ្ញុំមកខ្ញុំលើកបន្លែរ លក់ត្រីងៀតលក់អីអញ្ចឹងទៅនៅផ្សារកាប់គោ
ឯណោះទិញត្រីងៀតពីផ្សារថ្មី!

ក៖ ចាស!

ខ៖ យកមកលើកមកលក់នៅផ្សារកាប់គោ!

ក៖ អឺម...ចាសលោកយាយ!

ខ៖ រហូតដល់ឆ្នាំ៧៣(ឆ្នាំ១៩៧៣) ខ្ញុំចេញទៅវិញ!

ក៖ ចាស!

ខ៖ អត់នៅដល់៧៥ទេ ៧៥បានគេបែកភ្នំពេញ!

ក៖ ចាស!
អញ្ចឹងបានលោកយាយបានឈប់ការងារនឹងរហូតមកបានមកដល់នេះស្នាក់នៅនឹងវត្តឬក៏អីលោកយាយ?

ខ៖ អឺម!
ដល់...អត់ទេយូរដែរនៅរកស៊ីធ្វើ...ធ្វើស្រែនឹងយូរហើយដែរទាល់តែកូនស្លាប់តើបានខ្ញុំមកនៅនឹងភ្នំពេញនឹងមកចិញ្ចឹមចៅណាស់!

ក៖ ចាស!

ខ៖ ដល់ពេលកូនរបស់ខ្ញុំស្លាប់ទៅខ្ញុំមកចូលខ្លួនមកចិញ្ចឹមចៅ
ចៅវាកំព្រាហើយកូនប្រសារនោះវាអត់បងប្អូនទៀតវាអត់មានទីពឹងទៅទៀតមានតែខ្ញុំជាម្ដាយក្មេកឪពុកក្មេកមួយជួយមើលជួយចិញ្ចឹមម្ដាយនោះទៅធ្វើការនៅអង្គការម៉ារីណុល
ហើយខ្ញុំនៅចាស់ៗនឹងនៅមើលចៅមើលអីចិញ្ចឹមចៅ!

ក៖ ចាស! ហ៊ឹម...យាយអើយ!

ខ៖ ពង្សប្រវត្តិរបស់ខ្ញុំបើនិយាយទៅខ្ញុំពិបាកនឹងសព្វណាស់
វាអត់មានកូនមានអីនឹងគេកូនរបស់ខ្ញុំមានតែមួយនឹងដល់ពេលវាស្លាប់ទៅ
ខ្ញុំចិញ្ចឹមចៅដោយវេទនាណាស់
ទម្រាំតែចៅធំប្រឹងរៀនបើមីចៅស្រីមួយនោះរៀនបណ្ដើរធ្វើបណ្ដើរយកលុយដើម្បីបង់សាលា

រៀនរហូតដល់ឥលូវនឹងវាបានរៀនចប់បរិញ្ញាប័ត្រហើយមីស្រីនឹងមានប្តីហើយការកាលខែដប់ពីរនឹងណាស់!

ក៖ ចាស!

ខ៖ ចាសចៅស្រីមានតែមួយទេ ចៅប្រុសបី!

ក៖ ចាសលោកយាយ!
យាយហើយអឺ...លោកយាយរាល់ជឿរលើព្រះពុទ្ធសាសនាអញ្ចឹងអឺ...បានរយះពេលយូរហើយហ៏លោកយាយ?

ខ៖ យូរហើយខ្ញុំជឿរទៅលើព្រះពុទ្ធសាសនានឹង ខ្ញុំមកនៅបំរើលោកយូរឆ្នាំហើយ!

ក៖ អឹម!
ហើយលោកយាយព្រះពុទ្ធសាសនានឹងជះឥទ្ធិពលអីគេខ្លះទៅជីវិតរបស់លោកយាយ?

ខ៖ អឹម!
ទេអានឹងរឿងនៅក្នុងព្រះពុទ្ធសាសនាជំនឿរបស់នែ...ខ្មែរយើងឥលូវនឹងមិនមែនត្រឹមតែខ្មែរយើងទេគេសាសន៍គេក៏គេជឿរទៅលើព្រះពុទ្ធសាសនាដែរ
អឹម...រឿងអីក៏ដោយគេតែងតែជំនឿរលើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ
ជឿរព្រះជឿរអានឹងថាទៅដូចថាយើងធ្វើបុណ្យទៅបានបុណ្យ ធ្វើបាបបានបាប!

ក៖ អឹម! ចាសលោកយាយ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់!

ខ៖ នឹងហើយធ្វើល្អបានល្អ នឹងយើងយកមកព្រះពុទ្ធ ព្រះធម៌
ព្រះសង្ឃធ្វើជាស្ពានសំរាប់យើងឆ្លងទៅខាងមុខណាស់ វាមានន័យអញ្ចឹងណាស់!

ក៖ ចាស!

ខ៖
ព្រោះអីបើវាមានកម្មពៀរវេរាអីទាំងប៉ុន្មាននឹងសូមអោយរំដោះកម្មពៀរវេរាជាតិនេះទៅជាតិមុខអីកុំអោយមានកម្មពៀរវេរាដូចខ្ញុំពិបាកអញ្ចឹងណាស់
ខ្ញុំផ្សងខ្ញុំប្រាថ្នាអញ្ចឹងណាស់ដែលខ្ញុំមកនៅធ្វើបុណ្យខ្ញុំនៅបំរើ(យាយនិយាយក្រៅសាច់រឿង)
អឹម...មកបំរើព្រះសង្ឃដើម្បីយកសេចក្តីសុខ

ទៅជាតិក្រោយដើម្បីជាស្ពានសំរាប់ខ្ញុំឆ្លងទៅខាងមុខទៀតអោយលាចាកផុតទុក្ខផុតកម្មពៀរវេរាអីទាំងប៉ុន្មានសុំអោយខ្ញុំអស់កម្មអស់ពៀរនៅក្នុងជាតិនឹង...ជាតិនេះ!

ក៖ ចាស! អញ្ចឹងយាយៗមានបទពិសោធន៏ច្រើនអញ្ចឹងរឿងបទពិសោធន៏ល្អនៅក្នុងជីវិតរបស់លោកយាយមានដែរឬទេ? ដែលធ្វើអោយលោកយាយសប្បាយចិត្តណាស់?

ខ៖ ឥលូវនឹងរាល់ថ្ងៃវាអត់សប្បាយនឹងតាឈឺ បើសិនជាកុំមានតាឈឺខ្ញុំសប្បាយណាស់!

ក៖ អឺម...តែរឿងពីមុនឡើយយាយមានដែរទេ?

ខ៖ មុន...មុនខ្ញុំអត់អីទេ មានអីទេ!

ក៖ អឺម...ចាស!
នឹងហើយយាយអញ្ចឹងយាយមានពាក្យពេចដ៏អីផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយដែរឬទេលោកយាយ?

ខ៖ អឺម! ពាក្យរាល់ថ្ងៃនេះប្រដៅកូនចៅថា ធ្វើម៉េចកូនចៅ
ធ្វើម៉េចដើរតែផ្លូវល្អកុំដើរផ្លូវអាក្រក់អឺម...ហើយអោយចេះធ្វើបុណ្យធ្វើទានចេះសន្សំកុសលចេះដាក់ទានមានលុយមានកាក់អីអោយធ្វើបុណ្យធ្វើទានទៅ
ហើយសូមអោយចៅដើរផ្លូវល្អផ្លូវត្រូវកុំដើរទៅតាមផ្លូវខុស!

ក៖ ចាស!

ខ៖ វាមិនបានសុខទេ តែងនិរាស្តព្រាត់ប្រាស់ម៉ែឪយាយតាបងប្អូនហើយ!

ក៖ អឺម!

ខ៖ អ្នកធ្វើ...អ្នកដៃដើរផ្លូវខុសនឹងឃើញតែផ្លូវដេកគុកនឹងអាខ្លះណាស់...អឺម...

ក៖ (សើច) ចាសអញ្ចឹងប៉ុណ្ណឹងចុះយាយន៏?

ខ៖ ចាសប៉ុណ្ណឹងចុះ!

ក៖ ចាសអរគុណយាយ!